គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៤០ ចេញផ្សាយថ្ងៃទី៦ ខែមេសា ឆ្នាំ២០២២
No. 40 Released on April 6, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# ការអនុញ្ញាត ឬការបដិសេធលើការស្នើសុំបង្កើតបរធនបាលកិច្ច

## Approval or Refusal of Trust Establishment



រូបភាព Picture: https://clevertap.com/blog/technical-documentation/

យោងតាមប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ក្នុងនាមបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាលដែលទទួលបានការអនុញ្ញាត និងតែងតាំងរួចរាល់ ត្រូវរៀបចំដាក់ពាក្យស្នើសុំបង្កើតបរធនបាលកិច្ចមក **ន.ប.ធ.** តាមទម្រង់និងផ្តល់ឯកសារភ្ជាប់ ដែលកំណត់ដោយអគ្គនាយកនៃ **ន.ប.ធ.**។ អគ្គនាយកនៃ **ន.ប.ធ.** ត្រូវឆ្លើយតបទៅបរធនបាលអំពីការបដិសេធក្នុងការបង្កើត ឬការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតបរធនបាលកិច្ច ក្នុងរយៈពេលមិនលើសពី១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំបង្កើតដោយភ្ជាប់មកជាមួយឯកសារពេញលេញ។ បន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យបង្កើតបរធនបាលកិច្ចភ្លាម បរធនបាលត្រូវបន្តនីតិវិធីចុះបញ្ជីបរធនបាលកិច្ច ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងតាមទម្រង់កំណត់ដោយអគ្គនាយកនៃ **ន.ប.ធ.**។ ការស្នើសុំចុះបញ្ជីបរធនបាលកិច្ច បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ឬបរធនបាលរូបវន្តបុគ្គលឯករាជ្យ ត្រូវបង្ហាញវត្តមាននៅ **ន.ប.ធ.** ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីបរធនបាលកិច្ច ស្របតាមបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច។

យ៉ាងណាមិញ ការស្នើសុំបង្កើតបរធនបាលកិច្ចអាចត្រូវបានបដិសេធដោយអគ្គនាយកនៃ **ន.ប.ធ.** ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំមិនអាចបំពេញតាមលក្ខខណ្ឌណាមួយដូចមានចែងក្នុងប្រការ៦, ប្រការ៧, ប្រការ៨, ប្រការ៩ ឬប្រការ១០ នៃប្រកាសនេះ។

According to the Prakas on the Rules for the Management, Organization and Functioning of the Trust, the approved and appointed trustee, on behalf of the Trustor or Trust Contributor, must apply for trust establishment using the form and provide attachments required by the Director General of the Trust Regulator **(TR).** Director General of the **TR** shall notify the trustee of the refusal or approval of the trust establishment within 15 (fifteen) working days after receiving the application, with complete documents attached. After immediately receiving the approval to establish the trust, the trustee must continue the trust registration procedures as stated in the laws and regulations in force and based on the form required by the Director General of the **TR**. For trust registration, the individual trustee of trust companies or independent individual trustee must present at the **TR** to apply for trust registration in line with the regulations enforced in trust sector.

Nevertheless, the application for the trust establishment may be declined by the Director General of the **TR**, in the case where the applicant fails to meet any of the conditions as stated in Article 6, Article 7, Article 8, Article 9 or Article 10 of this Prakas.

**អត្ថបទ÷ ជឹម ភ័ស្ត | Article: Chim Phorst**

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia www.trustregulator.gov.kh (855) 23 237 888
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh